**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ELECTRICITE DU CAMBODGE

**អគ្គិសនីកម្ពុជា**
លេខ: ០៤១០ សជណ.អក.ឧប

# សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិកបច្ចេកទេសអធិការកិច្ចអគ្គិសនីភ្នំពេញComptage MV ចំនួន០១រូប និង បុគ្គលិកបច្ចេកទេសអធិការកិច្ចអគ្គិសនីទី២ Comptage LV ចំនួន០១រូប ដើម្បីចូលបម្រើការងារនៅ **ការិយាល័យអធិការកិច្ចអគ្គិសនីភ្នំពេញ** ដូចខាងក្រោម :

*- **<u>លក្ខណៈសម្បត្តិបេក្ខជន</u>** :

- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.II.១ ក្នុងពេលសាកល្បងការងារ០៣ខែ ទទួលបាន៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សាវិស្វករអគ្គិសនីឡើងទៅ

*- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅ អគ្គិសនីកម្ពុជា។

*- បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ច្បាប់ដើមមកជាមួយ។ ករណី បេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជា មិនទទួលពាក្យជូនឡើយ។

*- **<u>បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ</u>** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យាសម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន ០១ ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ | ចំនួន ០១ ច្បាប់ |
| - តារាងពិន្ទុ (TRANSCRIPT) | ចំនួន ០១ ច្បាប់ |
| - ច្បាប់ដើម និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | ចំនួន ០១ ច្បាប់ |

*- **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម។**

*- **<u>ទីកន្លែងទទួលពាក្យ</u>** : នៅកីឡដ្ឋានបាល់ទាត់អគ្គិសនីកម្ពុជា(អតីតរោងចក្រអគ្គិសនីទី៤)។

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២៣ រៀងរាល់ថ្ងៃធ្វើការ

**<u>ពេលព្រឹក</u>** ចាប់ពីម៉ោង០៨:០០ ដល់ម៉ោង១១:៣០ **<u>ពេលល្ងាច</u>** ចាប់ពីម៉ោង១៤:០០ ដល់ម៉ោង១៧:០០

*- **<u>ព័ត៌មានផ្សេងៗ</u>**:សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃ សុក្រ ១៤កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**កែវ_គន្ធា**

**<u>បញ្ជាក់</u>**
- សេចក្តីជូនដំណឹងនេះ ធ្វើកាផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច "ព័ត៌មានវិជ្ជាជីវៈ " ។